# សាររំលឹក ឃាដករស៊ីឈ្នួល !!

- បានដាក់ប្រកាស ដោយ ដើមត្នោត មួយ ខែ មេសា 26, 2009 វេលា 5:50pm ក្នុង ទូទៅ
- ផ្ញើសារ បន្ថែម ជាមិត្តភក្តិ មើលការពិភាក្សា

សេរីភាពបញ្ចេញមតិ ជាសេរីភាពមូលដ្ឋាន ក្នុងចំណោមសេរីភាពមូលដ្ឋាន ដទៃ (មើល ១), មើល ២ ត្រូវតែមានសំរាប់មនុស្សគ្រប់រូប លើកលែងក្នុងរបបកុំមុយនីស្តផ្តាច់ការ (ប្រទេសយួន, ប្រទេសលាវ, ប្រទេសគុយបា, ប្រទេសខរៀខាងជើង, ប្រទេសចិន, ...) ឬក្នុងរបបយោធាផ្តាច់ការ (ប្រទេសភូមា, ...) ឬ ក្នុងរបបផ្តាច់ការដទៃ (ប្រទេសអ៊ីរ៉ាណ, ពួកប្រទេសនៅទ្វីបអាហ្វ្រិក, ...) ឬ នៅប្រទេសខ្មែរ ដែលលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស តែសំបកក្រៅ ឯធាតុពិតជាអំពើផ្តាច់ការ អំណាចក្នុងកណ្តាប់ដៃតែមនុស្សម្នាក់ (ក្នុងកណ្តាប់ដៃហ៊ុន សែន ដូចដែលលោកយ៉ាស ហ្គាយ, បេសកជនពិសេស អង្គការសហប្រជាជាតិ និយាយមិនខុសមែន)។

ខ្មែររាល់ថ្ងៃ សំគាល់ថា ឃាដករស៊ីឈ្នួល បានប្រើប្រាស់ក្រមអក្សរខ្មែរយូនីកូដ-នីដាសរសេរបានច្រើនមែន ប៉ុន្តែពាក្យសំដីរិះគន់ អំបាល់មាននោះ មិនគួរប្រើប្រាស់ ទៅលើកូនខ្មែរ លើបណ្តាញសង្គម ឬ លើអិនធើណែត ដែលគេម្នាក់ៗ បាន/កំពុងខិតខំ សរសេរបញ្ចេញវិចារ អភិវឌ្ឍក្រមអក្សខ្មែរ លើអិនធើណែត ព្រមទាំងវិភាគគ្រប់បញ្ហា ក្នុងនោះមានបញ្ហានិយាយស្តីបែបព្រៃ អា ម៉ឹង ហ្អែង ... របស់ហ៊ុន សែនជាដើម ដែលទាំងអ្នកហែអើហ៊ុន សែនគ្មានពេញចិត្ត សំដីបែបព្រៃទាំងនោះដែរ។

ទោះយ៉ាងណា ឃាដករស៊ីឈ្នួល កំពុងជានិស្សិតខ្មែរ រៀនសូត្រនៅប្រទេសបែលហ្សិកយ៉ាងហោចណាស់ ក៏បានជ្រួតជ្រាបអរិយធម៌ ប្រទេសជឿនលឿន ដែលគេគ្មានប្រើប្រាស់សំដី បែបគ្រាន់បើ តែជាមួយអ្នកមិនតបត។

បើឃាដករស៊ីឈ្នួល ពិតជាមានទេព្យកោសល្យរិះគន់មែន, ឃាដករស៊ីឈ្នួល គួរតែ ៖
- ប្រើប្រាស់ ពាក្យសំដីរិះគន់ទាំងនោះ រិះគន់អំពើផ្តាច់ការគ្រាន់បើជាមួយខ្មែរដូចគ្នា របស់ហ៊ុន សែន ដែលបច្ចុប្បន្នហ៊ុន សែនកំពុងភ្លេងភ្លាង មើលថោកគ្រប់ស្រីខ្មែរ (ករណីអ្នកស្រីតំណាងរាស្ត្រ មូង សុខហួរ ) នោះ។
- ប្រើប្រាស់ ពាក្យសំដីរិះគន់ទាំងនោះ រិះគន់ រដ្ឋាភិបាលខ្មែរ ដែលអនុញ្ញាតិលំហូរពួកយួន

អន្តោប្រវេស រស់នៅពេញប្រទេសខ្មែរ
- ប្រើប្រាស់ពាក្យសំដីរិះគន់ទាំងនោះ រិះគន់ប្រទេសយួន ដែលកំពុងកៀបសង្កត់ខ្មែរកម្ពុជាក្រោម នោះ

បើបានដូច្នោះមែន, នោះនឹងប្រាកដជាត្រូវបានទទួលការសរសើរ ពីគ្រប់កូនខ្មែរ !!! ផ្ទុយទៅវិញ បើក្លែងក្លាយ តែជាមួយអ្នកគេមិនត ដូចករណីហ៊ុន សែនធ្លាប់ក្លែងក្លាយ ច្បាស់ជាគ្មានកូនខ្មែរ ណាសរសើរទង្វើនោះទេ!!

ខ្មែររាល់ថ្ងៃ អបអរគ្រប់ការចូលរួម ពីគ្រប់សមាជិក។ ខ្មែររាល់ថ្ងៃ មិនទទួលពាក្យសំដីគ្មានសមហេតុផល (non-logic) ព្រមទាំងលំអក់ទំនាក់ទំនង រវាងកូនខ្មែរ ដែលខិតខំអភិវឌ្ឍក្រមអក្សរខ្មែរយូនីកូដ នោះទេ។

ជាទីបញ្ចប់ ជឿជាក់ថា ឃាដករស៊ីឈ្នួល នឹងយល់ពីទាំងអស់អ្វី បានរៀបរាប់ខាងលើ, កែប្រែសមរម្យឡើងវិញ អត្តបទរបស់ខ្លួន និងបង្វែរទិសរិះគន់ទង្វើមិនគប្បី របស់រដ្ឋាភិបាលខ្មែរ និង ទង្វើរបស់យួន ដែលកៀបសង្កត់ សេរីភាពបញ្ចេញមតិ របស់ខ្មែរកម្ពុជាក្រោម។ ការបង្វែរទិសរិះគន់បែបនោះ នឹងជាទង្វើ ពេញដោយគំនិតអភិវឌ្ឍប្រទេសខ្មែរ ពិតប្រាកដ។

បញ្ជាក់ ៖
- ឃាដករស៊ីឈ្នួល ត្រូវតែបញ្ឈប់ទង្វើ ជាពាក្យសំដី ប៉ះពាល់អារម្មណ៍សមាជិកដទៃលើបណ្តាញសង្គម
- សមាជិក លើបណ្តាញសង្គម គ្មានកោតក្រែង ទង្វើបែបនោះទេ ប៉ុន្តែជាទង្វើរមេខាន ពួកគេ
- ក្រុមអ្នកអភិបាល គ្មានញញើតដកចេញ សមាជិកភាព របស់អ្នកដែលរំខានជានិច្ចកាល សមាជិកដទៃ លើបណ្តាញសង្គម ទេ